**អន្តរប្បវីរ**
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ៖ សូមថ្វាយព្រះពរព្រះករុណាសម្តេចនរោត្តម-សីហនុ អតីតព្រះមហាក្សត្រខ្មែរ គួរផ្តល់ធម៌អប់រំដល់ខ្មែរជំនាន់ក្រោយ ប្រសើរជាងផ្តល់ចំរៀង ។

**Website: www.hoksavann.org**

ថ្ងៃទី៣១ ឧសភា ២០១០



ព្រះករុណាសម្តេចនរោត្តម-សីហនុ អតីតព្រះមហាក្សត្រខ្មែរ ទោះបីព្រះអង្គចូលនិវត្តន៍ទៅហើយក៏ដោយ ក៏ព្រះអង្គជាវរជនមានការពិសោធន៍ក្នុងផ្លូវនយោបាយ មានខុសមានត្រូវជាងកន្លះសតវត្សរ៍ គួរអ្នកកាន់អំណាចខ្មែរបច្ចុប្បន្ននេះ ទុកព្រះអង្គជាទីប្រឹក្សាជាប់ខ្ពស់ មានកិច្ចការសំខាន់ៗជាអាយុជីវិតរបស់ជាតិ គួរទៅពិគ្រោះសុំយោបល់ពីព្រះអង្គ ដូចជាបញ្ហាទឹកដីជាមួយប្រទេសជិតខាង ដែលមានទស្សនៈផ្ទុយយោបល់គ្នាអំពីអ្នកកាន់អំណាចនិងគណបក្សប្រឆាំង អង្គការក្រៅរដ្ឋាភិបាល និងពលរដ្ឋដែលនៅតាមប្រទល់ដែន ដែលបានបាត់បង់ទឹកដីជាដើម ។ បើសកម្មភាពបែបនេះកើតមាន ទើបការលើកសរសើរព្រះអង្គថាជាវីរក្សត្ររបស់ជាតិខ្មែរ ចេញពីចិត្តពិតមែន ពុំមែនគ្រាន់តែសរសើរសំបកក្រៅដោយទុកព្រះអង្គគ្រាន់តែលំអឲ្យគណបក្សកាន់អំណាចឡើយ ។

អតីតព្រះមហាក្សត្រខ្មែរមានព្រះជន្មចូលវ័យជរាហើយតាមធម្មតាធម៌ ដូច្នេះគួរឆ្លៀតពេលសរសេរបណ្តាំជាចុងក្រោយ ដូចជាព្រះសម្ពុទ្ធមុនព្រះអង្គបរិនិព្វាន ព្រះអង្គបានប្រទានឱវាទជាចុងក្រោយដល់សាវ័កដល់ពុទ្ធបរិស័ទរបស់ព្រះអង្គ កុំឲ្យមានសេចក្តីធ្វេសប្រហែស ត្រូវខំប្រឹងប្រែងធ្វើប្រយោជន៍ខ្លួននិងប្រយោជន៍សង្គមឲ្យបានសំរេចព្រោះសង្ខារមិនទៀងទេ ។ ពាក្យបណ្តាំជាអនុសាសន៍ជាលាយលក្ខអក្សរនេះមានប្រយោជន៍សំខាន់ណាស់ សំរាប់ជនជាតិខ្មែរគ្រប់ឋានៈ ជាពិសេសសំរាប់សិស្សនិស្សិតខ្មែរស្រាវជ្រាវទុកជាមេរៀន សំរាប់ឆ្លុះបញ្ចាំងមើលអតីតកាលរបស់អ្នកដឹកនាំ តើមានគុណសម្បត្តិគុណវិបត្តិនយោបាយ រហូតធ្វើឲ្យជនជាតិខ្មែរស្លូតត្រង់រងទុក្ខវេទនាគួរឲ្យរន្ធត់ក្នុងពីរបីទសវត្សរ៍កន្លងមកនេះ ។ អនុសាសន៍នេះបានជាឯកសារពិគ្រោះសំរាប់សិស្សនិងនិស្សិត ដែលជាអនាគតនៃប្រទេសកម្ពុជាឲ្យរស់រានមានជីវិត ចេញផុតពីការបែកបាក់គ្នា និងការឈ្លានពានពីបរទេស ។

ជំនួសព្រះសូរសៀងតាមរយៈចំរៀង គួរធ្វើអនុសាសន៍ផ្តាំផ្ញើដល់ខ្មែរជំនាន់ក្រោយ ដោយព្រះបន្ទូលផ្ទាល់ ឲ្យប្រុងប្រយ័ត្នចំពោះអនាគតនៃប្រទេសកម្ពុជា តើត្រូវប្រើមធ្យោបាយបែបណា ដើរតាមផ្លូវណា ដើម្បីឲ្យប្រទេសកម្ពុជាស្ថិតនៅគង់វង់ ? អនុសាសន៍នេះពុំមែនមានន័យថាធ្វើនយោបាយឡើយ តែជាព្រះយោបល់ ជាពាក្យផ្តាំផ្ញើ ក្នុងឋានៈជាព្រះបិតាជាតិដល់កូនចៅ ។ ដូចព្រះពុទ្ធជាម្ចាស់ព្រះអង្គទូន្មានព្រះបាទពិម្ពិសារ ព្រះបាទបសេនទិកោសល សុទ្ធតែជាព្រះមហាក្សត្រសោយរាជ្យគ្រប់គ្រងនគរ ឲ្យស្ថិតក្នុងព្រះរាជធម៌ មានទសពិធរាជធម៌ជាដើម ។ បានន័យថា ព្រះពុទ្ធជាម្ចាស់ព្រះអង្គពុំធ្វើនយោបាយដូចគ្រហស្ថទេ ប៉ុន្តែព្រះអង្គទូន្មានអ្នកនយោបាយដោយផ្លូវព្រះធម៌ ។ ក្រៅពីនោះ នៅមានកិច្ចឯទៀតជាច្រើនទៀតដែលត្រូវដាស់សតិខ្មែរឲ្យបំពេញដោយប្រុងប្រយ័ត្នទាំងផ្នែកវប្បធម៌និងផ្នែកសង្គមកិច្ច ។ ផ្នែកវប្បធម៌ មានវប្បធម៌បរទេសជ្រៀតចូលប្រទេសកម្ពុជា បើខ្មែរមិនប្រុងប្រយ័ត្នទេ អាចអស់អត្តសញ្ញាណរបស់ខ្លួន ដូចជាវប្បធម៌អាសអាភាស តាមរយៈទស្សនាវដ្តីវីដេអូ ការលួចនាំចូលគ្រឿងញៀនជាដើម ទាំងនេះជាគ្រឿងបំពុលយុវជននិងយុវនារីខ្មែរ ដែលជាធនធានមនុស្សរបស់ជាតិ ។ យើងដឹងហើយថា សម័យសកលភាវូបនីយកម្ម វាលូតលាស់ទាំងល្អលូតលាស់ទាំងអាក្រក់ ត្រូវធ្វើច្បាប់ទប់ទល់លូតលាស់ខាងអាក្រក់ ។ ដូចភ្លៀងធ្លាក់ វាដុះលូតលាស់ទាំងសន្ទូង លូតលាស់ទាំងស្មៅ គេត្រូវការកាត់ស្មៅចោល ហើយថែទាំសន្ទូងឲ្យលូតលាស់ល្អ ។ ផ្នែកសង្គមកិច្ច សព្វថ្ងៃនេះខ្មែរអត់ការងារ ក្រីក្រលំបាក ទៅធ្វើការនៅបរទេសត្រូវគេធ្វើបាប ។ គ្មានភ្លើងអគ្គិសនី គ្មានទឹកស្អាតប្រើប្រាស់ ពេលមានជម្ងឺគ្មានមន្ទីរពេទ្យគ្រប់គ្រាន់ព្យាបាលរោគជាដើម ។ អតីតព្រះមហាក្សត្រខ្មែរអាចដាស់តឿន ដើម្បីឲ្យបំពេញកង្វះខាតទាំងនោះ ប្រសើរជាងចំណាយកម្លាំងច្រៀងចំរៀង ប៉ុន្តែការធ្វើអនុសាសន៍គ្រាន់តែហៃអើ ក៏មិនមានប្រយោជន៍ឡើយ ។

ការច្រៀងចំរៀងចាត់ចូលក្នុងកាមគុណ សំរាប់មនុស្សសាមញ្ញដែលសប្បាយក្នុងកាមលោកិយ៍ ចំពោះឥស្សរជនមានព្រះមហាក្សត្រជាដើម ជាជនជាន់ខ្ពស់ គួរយកពេលវេលាទៅគិតពីបញ្ហាជាតិ មិនគួរចំណាយពេលវេលាទៅច្រៀងចំរៀងដែលជារបស់មនុស្សសាមញ្ញ ហើយបញ្ជាឲ្យគេចាក់ផ្សាយតាមទូរទស្សន៍ជាតិបែបនេះទេ ។ អ្នកចាក់គេចេះតែចាក់ គេចេះតែសរសើរហើយ ប៉ុន្តែក្នុងចិត្តរបស់គេស្របតាមការសរសើរនោះឬទេ គ្មានអ្នកណាមើលឃើញឡើយ ។ អ្នកមើលព្រះអតីតព្រះមហាក្សត្រច្រៀងតាមទូរទស្សន៍ ទោះបីមិនពេញចិត្ត ក៏គេមិនហ៊ានពោលរិះគន់ឡើយ ព្រោះអតីតព្រះមហាក្សត្រក៏មានអភ័យឯកសិទ្ធិដូចព្រះមហាក្សត្រសោយរាជ្យដែរ ។ ការយល់ថា ការច្រៀងការរាំនាំឲ្យអាយុវែង នាំឲ្យមានសុខភាពល្អ ពុំមែនជាការពិតឡើយ តាមព្រះពុទ្ធសាសនាថា កើតគឺការស្ងប់ផ្លូវចិត្ត គឺស្ងប់ចិត្តចេញពីកាមគុណទាំង៥វិញទេ ។ ដូច្នេះអតីតព្រះមហាក្សត្រខ្មែរគួរផ្តល់ធម៌អប់រំដល់ខ្មែរជំនាន់ក្រោយ ប្រសើរជាងផ្តល់ចំរៀង ។

ការធ្វើសំណើសុំព្រះមហាក្សត្រឲ្យទៅជាទីប្រឹក្សាជាន់ខ្ពស់របស់រាជរដ្ឋាភិបាលខ្មែរ ដើម្បីសុំយោបល់ព្រះអង្គក្នុងបញ្ហាសំខាន់ៗជាអាយុជីវិតរបស់ជាតិ មានទឹកដីជាដើម ជំនួសការផ្តល់ចំរៀងនេះ ពិតជាមានមតិមួយជ្រៀតមកថា គេមិនសង្ឃឹមថា អតីតព្រះមហាក្សត្រខ្មែរមានព្រះជំហររឹងមាំការពារទឹកដីឡើយ ព្រោះគេឃើញសន្និសញ្ញាបំពេញបន្ថែមដែលព្រះមហា

ក្សត្រខ្មែរបច្ចុប្បន្នចុះព្រះហត្ថលេខា ក៏មានការយល់ស្របពីព្រះបិតាដែរ ។ សន្ធិសញ្ញាបំពេញបន្ថែមនោះ គេយល់ថាជាសន្ធិ
សញ្ញាធ្វើឲ្យខ្មែរបាត់បង់ទឹកដី ។ ប៉ុន្តែបើគេពិនិត្យមើលព្រះបន្ទូលរបស់អតីតព្រះមហាក្សត្រខ្មែរកាលពីឆ្នាំ២០០៥វិញ ព្រះ
អង្គថ្កោលទោសប្រទេសវៀតណាមយ៉ាងខ្លាំង ថាវៀតណាមបានរំលោភយកទឹកដីខ្មែរតាមព្រំប្រទល់ដែន ដោយរំលោភ
យ៉ាងជ្រៅចូលមកដីខ្មែរ ។ ព្រះបន្ទូលនេះអាចចាត់ទុកថា ព្រះអង្គជាអ្នកស្នេហាជាតិការពារទឹកដី ។ ក្រោយមកទៀត ព្រះអង្គ
មានព្រះបន្ទូលថា បើព្រះអង្គធ្វើជាប្រធានដោះស្រាយបញ្ហាព្រំប្រទល់ដែននេះ ព្រះអង្គនឹងចុះទៅវាស់ផ្ទាល់ម្តងមួយម៉ែត្រៗ
។ ព្រះបំណងនេះបានត្រូវរលាយ ដោយព្រះអង្គមិនបានធ្វើជាប្រធានផង ហើយបានត្រូវគំរាមពីប្រមុខដឹកនាំរដ្ឋាភិបាលផង
ថា បើសន្ធិសញ្ញាបំពេញបន្ថែមនេះមិនបានត្រូវព្រះមហាក្សត្រឡាយព្រះហត្ថលេខាទេ បញ្ហាព្រះមហាក្សត្រនឹងលើកយក
មកពិចារណាថា ប្រទេសកម្ពុជានឹងជារាជាណាចក្រឬជាសាធារណរដ្ឋ ។ បន្ទាប់ពីសន្ធិសញ្ញាបំពេញបន្ថែមបានត្រូវឡាយ
ព្រះហត្ថលេខាមក អតីតព្រះមហាក្សត្រខ្មែរមានព្រះបន្ទូលថា ដោយសារមានសហការដូចនេះ សូមឲ្យយល់ដល់ព្រះរាជ
បុត្ររបស់ព្រះអង្គផង ។ សូមបញ្ញវ័ន្តខ្មែរពិចារណាប្រកបដោយសុភវិនិច្ឆ័យចំពោះអ្នកដឹកនាំខ្មែរ ដែលចង់ឈ្នះចាញ់គ្នា
ទោះបីបាត់បង់ទឹកដីក៏ដោយ ។ ដើម្បីឲ្យកម្ពុជាគង់វង់ គឺត្រូវឲ្យមានឯកភាពជាតិ ប្រកបដោយប្រជាធិបតេយ្យ ត្រូវបញ្ឈប់
ការកំចាត់គ្នាក្រៅច្បាប់ ។៚

❈ ❈

❈